# មេរៀនទី ១០៧៖ ព្រះមេស្ស៊ីប្រសូតហើយ

លូកា ២៖១-២០; ហេព្រើរ ១៖១-៤

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/pQpUDI4HGiY

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/241wlyYXKUM

**គោលបំណង៖** ព្រះយេស៊ូវប្រសូត

**ខគម្ពីរចងចាំ៖** លូកា ២៖១១ *"ដ្បិតនៅថ្ងៃនេះ មានព្រះអង្គសង្គ្រោះ១អង្គ ប្រសូតដល់អ្នករាល់គ្នានៅក្រុងហ្លួងដាវីឌ គឺជាព្រះគ្រីស្ទដ៏ជាព្រះអម្ចាស់។"*

**ចំរៀង** ( *យូធូបលីង* )៖

១. យប់ដ៏សុខសាន្ត https://youtu.be/2tmj1KqH-UQ

២. ន៏ឮពួកទេវច្រៀងបទ https://youtu.be/YdKl42L8W3o

៣. អបអរសាទរ https://youtu.be/K72xD0x_cyg

## ១. អធិស្ឋាន

## ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

## ៣. ល្បែងកំសាន្ត «ឱបប៉េងប៉ោះ»



សម្ភារៈដែលត្រូវការ៖ ប៉េងប៉ោង និងកៅអី

១. ចែកកុមារជា ២ក្រុម

២. ដាក់កៅអីនៅចុងម្ខាងទៀតនៃថ្នាក់រៀន

៣. ឲ្យប៉េងប៉ោង ៣ទៅកុមារគ្រប់ៗគ្នា ដោយពួកគេត្រូវដាក់ប៉េងប៉ោង នៅគៀបក្រោមក្លៀកសងខាង និងមួយដាក់នៅចន្លោះជើង។

៤. ពួកគេត្រូវព្យាយាមដើរដោយគៀបប៉េងប៉ោងនោះ ទៅឲ្យដល់ចុងថ្នាក់រៀន ហើយប្រគល់ឲ្យគ្រូ។

៥. ប្រសិនបើកុមារណាធ្វើឲ្យប៉េងប៉ោងជ្រុះនោះពួកគេមិនអាចរើសវាបានទេ ហើយគេនឹងចាញ់ល្បែងនេះ។

៦. ក្រុមណាដែលអាចជញ្ជូនប៉េងប៉ោងទៅដល់ចុងម្ខាងនៃថ្នាក់រៀនបានច្រើនជាងគេក្រុមនោះជាអ្នកឈ្នះ

៧. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា វាមិនងាយស្រួលនោះទេក្នុងការដើរដោយមានប៉េងប៉ោង៣នោះ។ នៅពេលដែលម៉ារាពពោះព្រះយេស៊ូវ វាគឺពិតជាមានការពិបាកណាស់ក្នុងការដេក ដើរ ឈរ អង្គុយក្នុងការធ្វើការប្រចាំថ្ងៃ។ ប៉ុន្តែគាត់បានផ្តល់កំណើតដល់ព្រះយេស៊ូវពីព្រោះទ្រង់ជាព្រះអង្គសង្គ្រោះរបស់យើងរាល់គ្នា។

## ៤. ការណែនាំមេរៀន

ថ្ងៃនេះយើងធ្វើការអបអរសាទរដល់ការប្រសូត្រមករបស់ព្រះយេស៊ូវ ពីព្រោះថាជិតដល់ថ្ងៃបុណ្យណូអែលហើយ។ ព្រះយេស៊ូវបានយាងមកផែនដីនេះ គឺដោយព្រោះព្រះទ្រង់បានស្រលាញ់មនុស្សលោកជាខ្លាំង ដូច្នេះហើយ ទើបទ្រង់បានចាត់ព្រះយេស៊ូវមក ដើម្បីបង្ហាញដល់មនុស្សគ្រប់គ្នាក្នុងលោកីយ៍នេះឱ្យបាន

ដឹងថា តើព្រះគឺជានរណា។ ថ្ងៃនេះពួកយើងមកទីនេះដើម្បី អបអរសាទរពីសេចក្តីស្រលាញ់ និងការប្រសូត្រមករបស់ព្រះយេស៊ូវ។ វាគឺជាការសំខាន់ណាស់ ក្នុងការចងចាំថា ថ្ងៃបុណ្យគ្រីស្ទម៉ាស ប្រារព្វធ្វើឡើងដើម្បីអបអរដល់ការប្រសូត្ររបស់ព្រះយេស៊ូវគ្រីស្ទ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ម៉ារា និងយ៉ូសែបរស់នៅណាសារ៉ែត ស្រុកកាលីឡេ។ ប៉ុន្តែស្តេចសេសារ-អូគូស្ទ បានចេញ ព្រះរាជឱង្ការ១ច្បាប់ ឲ្យមនុស្សទាំងអស់ដែលនៅដែនដីរ៉ូមបានចុះបញ្ជី។ នៅគ្រានោះ ពួកអ៊ីស្រាអែលត្រូវបានគ្រប់គ្រងដោយចក្រភពរ៉ូម។ នេះគឺមានន័យថា ប្រជាជនទាំងអស់ត្រូវតែធ្វើដំណើរទៅស្រុកកំណើតខ្លួន ដើម្បីចុះបញ្ជី។ នេះគឺមានន័យថា ម៉ារា និងយ៉ូសែបត្រូវធ្វើដំណើរទៅ បេថ្លេហិម ក្រុងរបស់ហ្លួងដាវីឌ ពីព្រោះពួកគាត់ទាំងពីរជាព្រះវង្ស ហើយជាព្រះញាតិនឹងហ្លួងដាវីឌដែរ។

ការធ្វើដំណើរនេះមិនងាយស្រួលនោះទេ សម្រាប់ម៉ារា និងយ៉ូសែប ដោយសារតែម៉ារាមានទម្ងន់។ នៅពេលដែលពួកគេបានធ្វើដំណើរទៅដល់បេថ្លេហិម ព្រះយេស៊ូវក៏បានប្រសូត្រនៅក្នុងក្រោលសត្វ និងបានដាក់ទ្រង់ផ្ទុំក្នុងស្នូកឈើ ដែលគេប្រើសម្រាប់ដាក់ចំណីឲ្យសត្វស៊ី។ នេះដោយសារតែមិនមានបន្ទប់ជួលសម្រាប់ពួកគេ។ ព្រះយេស៊ូវគឺជា ស្តេចលើស្តេច និងជាព្រះលើព្រះ ប៉ុន្តែទ្រង់បានប្រសូត្រនៅក្នុងកន្លែងដ៏តូចទាបបំផុត។ ព្រះទ្រង់បានប្រទានព្រះរាបុត្រាតែមួយ គឺព្រះយេស៊ូវមកកាន់លោកីយ៍នេះសម្រាប់យើងរាល់គ្នា។ ព្រះយេស៊ូវប្រសូត្រដើម្បីសង្គ្រោះអ្នក ដើម្បីផ្តល់ជីវិតដល់អ្នក និងដើម្បីជួយដល់អ្នក។ ប៉ុន្តែទ្រង់មិនបានរើសយកការប្រសូត្រនៅក្នុងរាជវាំង ឬក៏នៅក្នុងប្រាសាទនោះទេ។ ទ្រង់បានប្រសូត្រនៅកន្លែងដែលនៅជិតមនុស្សម្នាបំផុត។

តាមពិតមនុស្សក្រុមដំបូងដែលបានរៀនអំពីកំណើតរបស់ព្រះយេស៊ូវ ដែលជាព្រះមេស្ស៊ី គឺជាអ្នកគង្វាល។ ក្នុងអំឡុងពេលនេះ អ្នកគង្វាលមិនមែនជាមនុស្សសំខាន់ទេ។ ប៉ុន្តែមានទេវតាមួយរូបមកពីព្រះបានលេចមកឲ្យអ្នកគង្វាល ដែលជាមនុស្សថ្នាក់ទាប ដើម្បីប្រាប់ពួកគេអំពីព្រះយេស៊ូវ។

ព្រះមិនបានខ្វល់ថាអ្នកមាន ឬអ្នកក្រប៉ុនណានោះទេ។ ទ្រង់តែងតែរកមើលអស់អ្នកដែលបន្ទាបខ្លួនអ្នកដែលត្រូវការទ្រង់នៅក្នុងជីវិតរស់នៅរបស់ពួកគេ។ តើអ្នកត្រូវការព្រះនៅក្នុងជីវិតរស់នៅរបស់អ្នកដែរឬទេ? តើអ្នកចង់មានព្រះវត្តមានរបស់ព្រះនៅក្នុងជីវិតរបស់អ្នកដែរឬទេ? ដូច្នេះ ចូរអរសប្បាយចុះ ពីព្រោះព្រះយេស៊ូវបានប្រសូត្រហើយ! ទ្រង់យាងមកដើម្បីសង្គ្រោះអ្នក និងជួយដល់អ្នក! ចូរយើងអបអរសាទរការប្រសូតរបស់ព្រះយេស៊ូវក្នុងថ្ងៃបុណ្យណូអែលនេះ!

## ៦. សំនួរពិភាក្សា

១. តើម៉ារានិងយ៉ូសែបត្រូវទៅចុះបញ្ជីនៅឯណា? *(បេថ្លេហិម)*

២. តើព្រះយេស៊ូវបានប្រសូត្រនៅឯណា? *(ព្រះយេស៊ូវបានប្រសូត្រនៅក្នុងក្រោលសត្វ និងបានដាក់ទ្រង់ផ្ទុំក្នុងស្នូក នេះដោយសារតែមិនមានបន្ទប់ជួលសម្រាប់ពួកគេ)*

៣. ហេតុអ្វីបានជាព្រះចាត់ទេវតាឲ្យទៅប្រាប់អ្នកគង្វាលចៀម ពីដំណឹងល្អអំពីការប្រសូតរបស់ព្រះយេស៊ូវ ជំនួសឲ្យ ការទៅប្រាប់ដល់ស្តេច ឬអ្នកដឹកនាំសាសនានោះ?
*(ដោយសារពួកអ្នកគង្វាលមានចិត្តរាបទាប ហើយដឹងថាពួកគេត្រូវការព្រះយេស៊ូវ)*

៤. តើអ្នកអាចអបអរសាទរចំពោះថ្ងៃកំណើតរបស់ព្រះយេស៊ូវបានដោយរបៀបណា?
*(ទុកឲ្យកុមារជាអ្នកឆ្លើយ)*

## ៧. ល្បែងកំសាន្ត «ការបញ្ជូនប៉េងប៉ោង»

សម្ភារៈដែលត្រូវការ៖ ប៉េងប៉ោង



១. ចែកកុមារជា២ ឬ៣ក្រុម



២. ឲ្យកុមារម្នាក់មកពីគ្រប់ក្រុមឈរនៅចុងម្ខាងនៃថ្នាក់រៀន ដើម្បីកាន់ប៉េងប៉ោងសម្រាប់ក្រុមរបស់ពួកគេ។

៣. ឲ្យកុមារទី១ គ្រប់ក្រុម រត់ទៅចុងម្ខាងនៃថ្នាក់រៀន ដើម្បីយកប៉េងប៉ោងមួយពីអ្នកឈរកាន់ប៉េងប៉ោង។ បន្ទាប់មកពួកគេត្រូវរត់ត្រលប់មកកាន់សមាជិកក្រុមរបស់ខ្លួនវិញ រួចដាក់ប៉េងប៉ោងនៅចន្លោះកណ្តាល ហើយរត់ទៅយកប៉េងប៉ោងមួយទៀត។ បន្តលេងល្បែងនេះរហូតដល់សមាជិកក្រុមបានលេងទាំងអស់គ្នា។



៤. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា វាមិនមែនជាការងាយស្រួលសម្រាប់ព្រះយេស៊ូវដែលបានប្រសូត្រមកក្នុងលោកីយ៍នេះ ប៉ុន្តែតាមរយៈការជួយរបស់ មនុស្សជាច្រើន ការប្រសូត្ររបស់ទ្រង់ក៏ត្រូវបានគេអបអរសាទរឡើង។

**៨. ខគម្ពីរចងចាំ**

**លូកា ២៖១១** *"ដ្បិតនៅថ្ងៃនេះ មានព្រះអង្គសង្គ្រោះ១អង្គ ប្រសូតដល់អ្នករាល់គ្នានៅក្រុង ហ្លួងដាវីឌ គឺជាព្រះគ្រីស្ទដ៏ជាព្រះអម្ចាស់។"*

**៩. ហត្ថកម្ម "អំណរដល់លោក ព្រះបុត្រប្រសូត"**

សម្ភារៈដែលត្រូវការ៖ ព្រីនក្រដាសហត្ថកម្ម( ខាងក្រោម ) កូល័រ កន្ត្រៃ និងការបិត




១.ឲ្យកុមារផាត់ពណ៌ក្រដាសហត្ថកម្មនោះ។

២. ឲ្យកុមារកាត់តាមបន្ទាត់ដិតពណ៌ខ្មៅ ហើយបត់តាមបន្ទាត់ដាច់ៗ ហើយបិតវាធ្វើជាស្រោមសំបុត្រ។

៣. បិតក្រដាសដែលសរសេរថា "អំណរដល់លោក ព្រះបុត្រប្រសូត្រ" នៅពីមុខស្រោមសំបុត្រ។

៤. បិតរូបផ្កាយនៅផ្នែកខាងលើបំផុតនៃស្រោមសំបុត្រ។

៥. ដាក់រូបព្រះបុត្រយេស៊ូវនៅក្នុងសំបុត្រនោះ ហើយព្យួរវានៅកន្លែងណាក៏បាននៅក្នុងផ្ទះ ដើម្បីរំលឹកពួកយើងថា ព្រះយេស៊ូវប្រសូត្រមកដើម្បីសង្គ្រោះ និងជួយដល់ពួកយើង!

**១០. ចំរៀង** ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

**១១. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូ៖ ( សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន )**
ព្រះយេស៊ូវគឺជាអំណោយ និងតែងតែជាអំណោយបុណ្យណូអែលដ៏ល្អបំផុតដែលមិនធ្លាប់មាន! សូមអាន **ហេព្រើរ ១៖១-៤** ឡើងវិញ ជាវិធីមួយដើម្បីអបអរសាទរការពិតនៃបុណ្យណូអែល។ មិនថាអ្នកគិតយ៉ាងណាអំពីបុណ្យណូអែល នៅពេលដែលអ្នកធ្វើឱ្យព្រះយេស៊ូវផ្តោតអារម្មណ៍ វាក្លាយជាថ្ងៃឈប់សម្រាកដ៏ល្អបំផុតដែលមិនធ្លាប់មាន។ តើបុណ្យណូអែលគឺជាពេលវេលាដ៏រីករាយ សម្រាប់អ្នកមែនទេ? វត្តមានរបស់ព្រះយេស៊ូវអាចធ្វើឲ្យអ្នកកាន់តែរីករាយ។ តើបុណ្យណូអែលគឺជាពេលវេលាដ៏ សោកសៅសម្រាប់អ្នកមែនទេ? ព្រះយេស៊ូវអាចបំពេញចន្លោះ ដែលអ្នកមានអារម្មណ៍ថាខ្វះខាតនៃឆ្នាំនេះ។

ចែករំលែកសេចក្តីពិតរបស់ព្រះយេស៊ូវជាមួយនរណាម្នាក់នៅថ្ងៃនេះ។ ព្រះយេស៊ូវជាអំណោយដែលបានផ្តល់ឲ្យមិនចេះអស់!

# អំណរដល់លោកព្រះបុត្រប្រសូត្រ











